**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកៅស៊ូ**

ថ្ងៃ...អង្គារ ៩កើត...ខែ...ស្រាពណ៍...ឆ្នាំ...ឆ្លូវ.......ស័ក ព.ស.២៥៦៥

លេខ: ៣៧៣ អក

រាជធានីភ្នំពេញ ថ្ងៃទី.....១៧...........ខែ.......សីហា...........ឆ្នាំ២០២១

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែកក្កដា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់** ៖-របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែកក្កដា ឆ្នាំ២០២១.......ចំនួន០១ច្បាប់

-តារាងស្ថានភាពផលិតកម្មកៅស៊ូ តារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូ និងតារាងផលិតផលឈើកៅស៊ូកែច្នៃ និងនាំចេញប្រចាំខែកក្កដា ឆ្នាំ២០២១.........................................ចំនួន០៤ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែកក្កដា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តសម្រាប់ចុះក្នុងរបាយការណ៍របស់ក្រសួងក្នុងខែសីហាដោយសង្ខេបដូចខាងក្រោម៖

## ១- ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៤ ១៦០ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ៣១៤ ៣១៩ហិកតា ស្មើនឹង៧៨% និងផ្ទៃដីថែទាំមានចំនួន ៨៩ ៨៤១ហិកតា ស្មើនឹង២២%។

## ២- ផលិតកម្មជ័រកៅស៊ូ និងឈើកៅស៊ូ

- ផលិតផលជ័រកៅស៊ូក្នុងខែកក្កដា មានចំនួន៣១ ៤៦៧តោន កើនឡើងចំនួន៧៤២តោន ស្មើនឹង២% ធៀបនឹងខែមុន និងបានកើនឡើងចំនួន៤ ៣៥២តោន ស្មើនឹង១៦% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

- ផលិតផលជ័រកៅស៊ូចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន១៦៤ ៩៥៧តោន បានកើនឡើងចំនួន១១ ៧៥៤តោន ស្មើនឹង៨% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

- ផលិតផលឈើកៅស៊ូសម្រេចបានប្រចាំខែកក្កដា មានចំនួន១០០ម³ មានការថយចុះ ៣៨៥ម³ ស្មើនឹង ៧៩% ធៀបនឹងខែមុន។

- ផលិតផលឈើកៅស៊ូចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ សម្រេចបានចំនួន៤ ៤១៩ម³។

## ៣- ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងខែកក្កដា មានចំនួន៣០ ៦៨២តោន បានកើនឡើងចំនួន ១ ៧៥១តោន ស្មើនឹង៦,០៥% ធៀបនឹងខែមុន និងបានកើនឡើងចំនួន២ ៣៥៩តោន ស្មើនឹង៨% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន១៦២ ០៨៧តោន បានកើនឡើងចំនួន១០ ៤៤៩តោន ស្មើនឹង៧%ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

- បរិមាណបញ្ចេញលក់ឈើកៅស៊ូសម្រេចបានក្នុងខែកក្កដា មានចំនួន ៤១១ម³ មានការថយចុះ ៧៤ម³ ស្មើនឹង១៥% ធៀបនឹងខែមុន។

-បរិមាណបញ្ចេញលក់ឈើកៅស៊ូចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដាឆ្នាំ២០២១ សម្រេចបានចំនួន៤០៧៤ម³។

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០

National Road No. 6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia Phone: (855) 23 6722 590, Email: gdr.maff@gmail.com

## ៤- តម្លៃជ័រកៅស៊ូ និងឈើកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែកក្កដា ថ្លៃ១ ៦១៥ដុល្លារ/តោន បានថយចុះចំនួន១២០ដុល្លារ/តោន ស្មើនឹង៦.៩០% ធៀបនឹងខែមុន និងបានកើនឡើងចំនួន៣៧៦ដុល្លារ/តោនស្មើនឹង៣០%ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

- តម្លៃលក់ជ័រកៅស៊ូមធ្យមចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ ថ្លៃ១ ៦៧៤ដុល្លារ/តោន បានកើនឡើងចំនួន៣៨៣ដុល្លារ/តោន ស្មើនឹង៣០% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

- តម្លៃលក់ឈើកៅស៊ូមធ្យមប្រចាំខែកក្កដា តម្លៃ៣១៧ដុល្លា/ម$^{៣}$ ។

- តម្លៃជ័រកៅស៊ូគ្រួសារនៅនឹងចម្ការ គឺទឹកជ័រ (DRC ១០០%) ថ្លៃ៥ ៧០០- ៦ ០០០៛/គ.ក្រ (បានថយចុះចំនួន៣២០៛/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC ៥០%) ថ្លៃ ២ ៥១៣ - ៣ ២៦៣៛/គ.ក្រ ថយចុះចំនួន៤៨៛/គ.ក្រ ធៀបនឹងខែមុន)អាស្រ័យតាមរយៈពេលបង្កកនិងតំបន់។

## ៥- ចំណូលពីការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូ

- **ចំណូលសរុបប្រចាំខែកក្កដា មានចំនួន៤៩ ៦៨៩ ០៧១ដុល្លារ**

- ចំណូលពីការនាំចេញជ័រកៅស៊ូក្នុងខែកក្កដា មានចំនួន៤៩ ៥៤៩ ៥៦១ដុល្លារ

- ចំណូលពីការនាំចេញឈើកៅស៊ូក្នុងខែកក្កដា មានចំនួន ១៣៩ ៥១០ដុល្លារ

- **ចំណូលសរុបប្រចាំខែកក្កដា ឆ្នាំ២០២១ មានចំនួន២៧២ ២៥០ ៥១៤.៨៤ដុល្លារ**

-ចំណូលពីការនាំចេញជ័រកៅស៊ូសរុបរហូតមកដល់ខែកក្កដាឆ្នាំ២០២១ មានចំនួន ២៧១ ៣៥៤ ០១២ដុល្លារ

-ចំណូលពីការនាំចេញឈើកៅស៊ូសរុបរហូតមកដល់ខែកក្កដាឆ្នាំ២០២១ មានចំនួន ៨៩៦ ៥០២.៨៤ដុល្លារ។

## ៦- ទិសដៅបន្ត

- បន្តខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

- បន្តសហការជាមួយក្រុមហ៊ុនចម្ការកៅស៊ូអវិនិយោគរបស់រដ្ឋ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចលើដំណាំកៅស៊ូ និងចម្ការកៅស៊ូគ្រួសារ ក្នុងការប្រមូលទិន្នន័យកៅស៊ូ ដើម្បីមានមូលដ្ឋានរាយការណ៍ច្បាស់លាស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បន្តសហការជាមួយអង្គការ សមាគមកៅស៊ូអន្តរជាតិនានា ដើម្បីទទួលបានព័ត៌មានស្តីពីស្ថិតិ និងនិន្នាការទីផ្សារកៅស៊ូសកលលោក សម្រាប់ផ្សព្វផ្សាយជូនដល់ប្រតិបត្តិករកៅស៊ូក្នុងស្រុក។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ហ៊ឹម អួន**

**ចម្លងជូនៈ**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

"ដើម្បីជ្រាប"

- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍
# ស្ដីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែកក្កដា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## ១-សេចក្ដីផ្ដើម

ក្នុងឆ្នាំ២០២១នេះ អគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារជាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែកក្កដា ឆ្នាំ២០២១ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១- ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៤ ១៦០ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន៣១៤ ៣១៩ហិកតា ស្មើនឹង ៧៨% និងផ្ទៃដីថែទាំមានចំនួន៨៩ ៨៤១ហិកតា ស្មើនឹង២២%។

### ២.២- ផលិតកម្មជ័រកៅស៊ូ និងឈើកៅស៊ូ

- ផលិតផលជ័រកៅស៊ូក្នុងខែកក្កដា មានចំនួន៣១ ៤៦៧តោន កើនឡើងចំនួន៧៤២តោន ស្មើនឹង២%ធៀបនឹងខែមុន និងបានកើនឡើងចំនួន៤ ៣៥២តោន ស្មើនឹង១៦% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន
- ផលិតផលជ័រកៅស៊ូចាប់ពីដើមឆ្នាំរហូតមកដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន១៦៤ ៩៥៧តោន បានកើនឡើងចំនួន១១ ៧៥៤តោន ស្មើនឹង៨% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន
- ផលិតផលឈើកៅស៊ូសម្រេចបានប្រចាំខែកក្កដា មានចំនួន១០០ម$^{៣}$ បានថយចុះ ៣៨៥ម$^{៣}$ ស្មើនឹង ៧៩% ធៀបនឹងខែមុន
- ផលិតផលឈើកៅស៊ូប្រចាំខែកក្កដា ឆ្នាំ២០២១ សម្រេចបានចំនួន៤ ៤១៩ម$^{៣}$។

### ២.៣- ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងខែកក្កដា មានចំនួន៣០ ៦៨២តោន បានកើនឡើងចំនួន១ ៧៥១តោន ស្មើនឹង៦% ធៀបនឹងខែមុន និងបានកើនឡើងចំនួន២ ៣៥៩តោន ស្មើនឹង៨% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន
- បរិមាណបញ្ចេញលក់ជ័រកៅស៊ូចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន១៦២ ០៨៧តោនបានកើនឡើងចំនួន១០ ៤៤៩តោន ស្មើនឹង៧%ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន
- បរិមាណបញ្ចេញលក់ឈើកៅស៊ូសម្រេចបានក្នុងខែកក្កដា មានចំនួន ៤១១ម$^{៣}$ បានថយចុះ៧៤ម$^{៣}$ ស្មើនឹង ១៥% ធៀបនឹងខែមុន
- បរិមាណបញ្ចេញលក់ឈើកៅស៊ូចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ សម្រេចបានចំនួន៤ ០៧៤ម$^{៣}$។

## ២.៤- តម្លៃជ័រកៅស៊ូនិងឈើកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែកក្កដា ថ្លៃ១ ៦១៥ដុល្លារ/តោន បានថយចុះចំនួន១២០ដុល្លារ/តោនស្មើនឹង ៦,៩០% ធៀបនឹងខែមុន និងបានកើនឡើងចំនួន៣៧៦ដុល្លារ/តោន ស្មើនឹង៣០%ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន

- តម្លៃលក់ជ័រកៅស៊ូមធ្យមចាប់ពីដើមឆ្នាំរហូតដល់ខែកក្កដា ឆ្នាំ២០២១ ថ្លៃ១ ៦៧៤ដុល្លារ/តោន បានកើនឡើងចំនួន៣៨៣ដុល្លារ/តោន ស្មើនឹង៣០% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន

- តម្លៃលក់ឈើកៅស៊ូមធ្យមប្រចាំខែកក្កដា ឆ្នាំ២០២១ តម្លៃ៣១៧ដុល្លា/ម៣។

- តម្លៃជ័រកៅស៊ូគ្រួសារនៅនឹងចម្ការ គឺទឹកជ័រ (DRC ១០០%) ថ្លៃ៥ ៧០០- ៦ ០០០រ/គ.ក្រ (បានថយចុះចំនួន ៣២០រ/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC ៥០%) ថ្លៃ២ ៥១៣ - ៣ ២៦៣រ/គ.ក្រ ថយចុះចំនួន៤៨រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមរយៈពេលបង្កកនិងតំបន់។

## ២.៥- ចំណូលពីការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូ

- **ចំណូលសរុបក្នុងខែកក្កដា មានចំនួន៤៩ ៦៨៩ ០៧១ដុល្លារ**

- ចំណូលពីការនាំចេញជ័រកៅស៊ូក្នុងខែកក្កដា មានចំនួន៤៩ ៥៤៩ ៥៦១ដុល្លារ
- ចំណូលពីការនាំចេញឈើកៅស៊ូក្នុងខែកក្កដា មានចំនួន ១៣៩ ៥១០ដុល្លារ

- **ចំណូលសរុបប្រចាំខែកក្កដា ឆ្នាំ២០២១ មានចំនួន២៧២ ២៥០ ៥១៤,៨៤ដុល្លារ**

-ចំណូលពីការនាំចេញជ័រកៅស៊ូសរុបរហូតមកដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន ២៧១ ៣៥៤ ០១២ដុល្លារ
-ចំណូលពីការនាំចេញឈើកៅស៊ូសរុបរហូតមកដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន ៨៩៦ ៥០២,៨៤ដុល្លារ។

# ៣. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ៣.១- ការងារចរន្ត

- ពិនិត្យធ្វើបច្ចុប្បន្នភាពស្ថិតិកៅស៊ូ ឆ្នាំ២០២១ កៅស៊ូផ្តល់ផល (Mature Area) កៅស៊ូថែទាំ(Immature Area) និងផ្ទៃដីបោះបង់(Discarded Area)
- ពិនិត្យនិងរៀបចំរបាយការណ៍ការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិខែកក្កដា-កម្ពុជាផ្ញើទៅលេខាធិការដ្ឋានANRPC
- ពិនិត្យនិងចងក្រងអត្ថបទបច្ចេកទេសកៅស៊ូ សម្រាប់ចុះផ្សាយក្នុងព្រឹត្តិបត្រប្រចាំខែរបស់អគ្គនាយកដ្ឋានកៅស៊ូ
- ពិនិត្យនិងតាមដានសកម្មភាពរបស់សហគមន៍កសិកម្មកៅស៊ូតាមខេត្ត(៩ខេត្ត)
- រៀបចំមេរៀន(បទបង្ហាញ)បច្ចេកទេសកៅស៊ូ សម្រាប់បណ្តុះបណ្តាលកសិករកៅស៊ូគ្រួសារ និងមន្ត្រីបង្គោល
- រៀបចំមេរៀនការចងក្រងសហគមន៍កសិកម្មនិងការដឹកនាំគ្រប់គ្រង សម្រាប់ការចុះពង្រឹងនិងបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារនៅខេត្តគោលដៅ
- ប្រជុំពិនិត្យលើការចំណាយរបស់ក្រុមហ៊ុន ដាយ ដុងយឿង ដាំដុះកៅស៊ូចំនួន៨០០ហិកតា នៅខេត្តរតនគិរី ក្រោមធិបតីភាពឯកឧត្តម គុយ ម៉ារិនឌី រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមរយៈប្រព័ន្ធវីដេអូហ្សូម (Zoom)
- ពិនិត្យនិងរៀបចំលិខិតណែនាំបច្ចេកទេសដល់ចម្ការកៅស៊ូអវិនិយោគទាំ៧ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមប្រជុំពិនិត្យនិងកែសម្រួលលើប្រធានបទជាភាសាខ្មែរ និងបកប្រែជាភាសាអង់គ្លេស សម្រាប់រៀបចំវីដេអូខ្លីៗ នៃការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រសម្រាប់ផ្សព្វផ្សាយដល់កសិករកៅស៊ូគ្រួសាររួមមានៈ

បទដ្ឋាននៃការបើកមុខចៀរដំបូង ការគ្រប់គ្រងផ្ទាំងចៀរ ការចៀរមុខលើ ការលាបថ្នាំរំញោច និងការថែទាំកៅស៊ូផ្តល់ផល ដោយសហការជាមួយអង្គការ WWF Cambodia និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមពិនិត្យ និងកែសម្រួលលើរបាយការណ៍សង្ខេបស្តីពីការចុះសិក្សារបស់អ្នកពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាលើវិស័យកៅស៊ូ សម្រាប់ការអភិវឌ្ឍគោលការណ៍កៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាពនៅកម្ពុជា ដោយផ្តោតជាសំខាន់ទៅលើគោលការណ៍និរន្តរភាពទាំង៥ រួមមាន (១)ការគោរពសិទ្ធមនុស្ស (២)ការការពារបរិស្ថាន (៣)ការធ្វើឲ្យប្រសើរឡើងនូវធនធានធម្មជាតិ(៤)ការលើកកម្ពស់ផលិតភាពកសិកម្ម និង(៥) អភិបាលកិច្ចល្អ
- តាមដាន ត្រួតពិនិត្យ ស្រាវជ្រាវអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅស្រុក ប្រមូលនិងចងក្រងទិន្នន័យថ្លៃទិញលក់កៅស៊ូធម្មជាតិ ប្រចាំថ្ងៃ
- បានស្រាវជ្រាវនិងបញ្ចូលថ្លៃកៅស៊ូនៅទីផ្សារអន្តរជាតិ និងនៅតាមទីផ្សារហ៊ុនផ្សេងៗប្រចាំថ្ងៃទៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានកៅស៊ូ
- ប្រជុំតាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យសម្រេចព្រឹត្តិបត្រកៅស៊ូធម្មជាតិខែមិថុនា វឌ្ឍនភាព ខែកក្កដា និងលើកទិសដៅខែសីហា ឆ្នាំ២០២១
- បានប្រជុំកម្រិតអន្តរនាយកដ្ឋានពិនិត្យនិងពិភាក្សាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គនាយកដ្ឋានកៅស៊ូ និងសម្ព័ន្ធសហគ្រាសកៅស៊ូវៀតណាមស្តីពីកិច្ចសហប្រត្តិបត្តិការក្នុងវិស័យកៅស៊ូនិងធ្វើកំណត់ហេតុរួមទាំងរបាយការណ៍លទ្ធផល
- រៀបចំឯកសារអនុស្សរណៈនៃការយោគយល់គ្នាជូនសមាជិកនៃអង្គប្រជុំ
- រៀបចំរបាយការណ៍វឌ្ឍនភាពបញ្ហាប្រឈមនិងទិសដៅអនាគតនៃកិច្ចសហប្រត្តិបត្តិការក្រោមក្របខណ្ឌCLV
- ប្រជុំពិភាក្សាលើគម្រោងផែនការចំណូល ចំណាយសម្រាប់ថវិកាកម្មវិធីឆ្នាំ២០២២
- រៀបចំរបាយការណ៍ស្តីពីធុរកិច្ចផលិតផលកៅស៊ូធម្មជាតិប្រចាំខែកក្កដា
- ស្រាវជ្រាវព័ត៌មានអំពីពន្ធនាំចេញកៅស៊ូនិងផលិតផលជ័រនិងឈើកៅស៊ូ
- បានប្រជុំកែសម្រួលការចុះត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការបច្ចេកទេសរបស់រោងចក្រ សិប្បកម្ម កែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ(RSSនិងADS)
- បានប្រជុំកែសម្រួលការចុះត្រួតពិនិត្យនិងវាយតម្លៃលើប្រតិបត្តិការបច្ចេកទេសរបស់រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស(TSR)
- បានចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការសិប្បកម្មកែច្នៃកៅស៊ូ TSR លេខ២៩៨អក ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកៅស៊ូឲ្យទៅលោក នេត សារី ម្ចាស់សិប្បកម្មកៅស៊ូនេតសារី

**៣.២- ការចំណាយថវិកាតាមគម្រោងកម្មវិធី**

ការចំណាយថវិកាក្នុងខែកក្កដា ឆ្នាំ២០២១ បានចំណាយថវិកាចំនួន១៤១ ៥៩៧ ៨៩៦រៀល។ ការចំណាយថវិការហូតមកដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន២១៨ ៩០៦ ៦២០រៀល ស្មើនឹង១៦,១០ភាគរយនៃផែនការ។

**៣.៣- ការប្រមូលចំណូលថវិកា**

ការប្រមូលចំណូលថ្លៃឈ្នួលដីអវិនិយោគចម្ការកៅស៊ូទាំង៧ ក្រុមហ៊ុននីហ៍វណា អាហ៍វណាកៅស៊ូ និងក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត (ចម្ការកៅស៊ូឡាបានសៀក)៖ ក្នុងខែកក្កដា មានចំនួន៩៨ ៣៩០ ៧១៨រៀល ទទួលបានពីការបង់ថ្លៃឈ្នួលដីចម្ការកៅស៊ូស្នូល។ ក្នុងនោះក្រុមហ៊ុន ស៊ីហ្វ រ៉ាប់ប៊ លីមីតធីត (ចម្ការកៅស៊ូឡាបានសៀក) មិនទាន់

បង់ថ្លៃឈ្នួលដីសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០។ បើគិតរហូតមកដល់ខែកក្កដានេះ អនុវត្តបានចំនួន ១ ២៦៥ ៨១៧ ៣៨០រៀល ស្មើនឹង៨៣,០៦ភាគរយនៃផែនការ។

**៤. ទិសដៅបន្ត**

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ
- បន្តសហការជាមួយអង្គការ WWF រៀបចំ Demonstration on GAP harvesting, រៀបចំ Video បច្ចេកទេស និងពង្រឹងសហគមន៍នៅខេត្តមណ្ឌលគិរី
- គ្រោងចុះផ្សព្វផ្សាយនិងពង្រឹងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារ
- រៀបចំមេរៀនសម្រាប់ចុះបើកវគ្គសិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោល
- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- ចុះពិនិត្យរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូ និងផ្សព្វផ្សាយប្រកាសលេខ០៤០ប្រក.កសក
- បន្តកែសម្រួលការចុះត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការបច្ចេកទេសរបស់រោងចក្រសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង និងកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ(RSS និងADS) និងការចុះត្រួតពិនិត្យនិងវាយតម្លៃលើប្រតិបត្តិការបច្ចេកទេសរបស់រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស(TSR)
- រៀបចំពិភាក្សាកែសម្រួលសៀវភៅណែនាំ ស្តីពីការកំណត់អត្តសញ្ញាណផ្លូវច្បាប់ទីតាំងនិងលក្ខខណ្ឌតម្រូវសម្រាប់សាងសង់រោងចក្រកែច្នៃកៅស៊ូនៅព្រះរាជាណាចក្រកម្ពុជា
- បន្តតាមដានការបង់ថ្លៃឈ្នួលដីអវិនិយោគ
- បន្តរៀបចំនិងតាមដានការផ្តល់ថវិកាកម្មវិធីឆ្នាំ២០២២
- ត្រួតពិនិត្យ បូកសរុបការកែច្នៃ និងការនាំចេញឈើកៅស៊ូ
- ចុះពិនិត្យរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូ និងផ្សព្វផ្សាយប្រកាស០៤០ប្រក.កសក។
- ប្រជុំពិនិត្យ សម្រេចព្រឹត្តបត្រកៅស៊ូធម្មជាតិប្រចាំខែមេសា វឌ្ឍនភាពខែឧសភា និងលើកទិសដៅខែមិថុនា
- ប្រជុំពិនិត្យវឌ្ឍនភាពនិងលើកទិសដៅអនុវត្តបន្តលើការងារគេហទំព័ររបស់អគ្គនាយកដ្ឋានកៅស៊ូ ឆ្នាំ២០២១ និងធ្វើរបាយការណ៍លទ្ធផល
- ស្រាវជ្រាវព័ត៌មានកៅស៊ូអន្តរជាតិនិងបញ្ចូលថ្លៃកៅស៊ូតាមទីផ្សារហ៊ុនផ្សេងៗក្នុង Website អគ្គនាយកដ្ឋានកៅស៊ូ
- បន្តខិតខំផ្សព្វផ្សាយតម្លៃជ័រកៅស៊ូធម្មជាតិ នៅលើទីផ្សារក្នុងស្រុកនិងអន្តរជាតិតាមបណ្តាញសង្គម (ហ្វេសប៊ុក) ឱ្យបានដល់កសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូ
- បន្តសិក្សាស្រាវជ្រាវផ្សព្វផ្សាយពត៌មាន អំពីការផ្គត់ផ្គង់តម្រូវការ ការប្រើប្រាស់កៅស៊ូធម្មជាតិនិងនិន្នាការតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា វិទ្យាសាស្ត្រ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំបានប្រគល់ឱ្យ។

ថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០២១

**បានឃើញនិងឯកភាព**

**ជ.ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**អគ្គនាយករង**

**ចាន់_វឌ្ឍនា**

**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

**ឃួន_ផល្លា**

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែកក្កដា ឆ្នាំ២០២១

តារាងទី២

| ល.រ | ចម្ការកៅស៊ូ | ២០២០ | | | | | | ២០២១ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | ថ្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | ថ្លៃមធ្យម($/តោន) | | បរិមាណ | | ថ្លៃមធ្យម | | បរិមាណ | | | | ថ្លៃមធ្យម | | | |
| | | | | | | | | | | | | | | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| | I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 45 | 190 | 50.850 | 212.160 | 1.130 | 1.117 | 110 | 481 | 171.600 | 773.320 | 1.560 | 1.608 | 10 | 10 | -90 | -5,45 | 65 | 144 | 291 | 153 | 430 | 38 | 491 | 44 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 2.317 | 9.085 | 2.884.586 | 11.526.487 | 1.245 | 1.269 | 1.249 | 9.106 | 2.123.399 | 16.224.586 | 1.700 | 1.782 | -93 | -6,94 | -129 | -7,07 | -1.068 | -46 | 21 | 0 | 455 | 37 | 513 | 40 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 126 | 609 | 150.885 | 751.329 | 1.198 | 1.234 | 210 | 840 | 307.020 | 1.311.030 | 1.462 | 1.561 | 210 | 100,00 | 1.462 | 100,00 | 84 | 67 | 231 | 38 | 265 | 22 | 327 | 27 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 769 | 2.591 | 967.780 | 3.575.405 | 1.258 | 1.380 | 541 | 2.270 | 950.635 | 4.065.548 | 1.757 | 1.791 | 77 | 16,67 | -104 | -5,61 | -229 | -30 | -321 | -12 | 500 | 40 | 411 | 30 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | | 169 | | 173.004 | 0 | 1.022 | | 225 | | 315.355 | 0 | 1.402 | 0 | 0 | 0 | 0 | 0 | 0 | 56 | 33 | 0 | 0 | 381 | 37 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស លីមីធីត(ស្នួល) | 383 | 2.343 | 456.052 | 2.974.866 | 1.191 | 1.269 | 499 | 3.181 | 814.692 | 5.003.712 | 1.634 | 1.573 | 74 | 17,34 | -42 | -2,53 | 116 | 30 | 838 | 36 | 442 | 37 | 303 | 24 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 420 | 1.936 | 532.350 | 2.660.854 | 1.268 | 1.375 | 300 | 1.510 | 408.000 | 2.131.700 | 1.360 | 1.412 | -50 | -14,29 | -62 | -4,37 | -120 | -29 | -426 | -22 | 93 | 7 | 37 | 3 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 135 | 838 | 164.025 | 999.175 | 1.211 | 1.192 | 100 | 348 | 135.950 | 480.950 | 1.360 | 1.382 | 0 | 0 | -90 | -6 | -35 | -26 | -490 | -58 | 148 | 12 | 190 | 16 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 50 | 459 | 60.750 | 537.874 | 1.215 | 1.172 | 100 | 302 | 135.050 | 419.550 | 1.351 | 1.389 | 50 | 100 | -102 | -7 | 50 | 100 | -157 | -34 | 136 | 11 | 217 | 19 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 777 | 2.717 | 956.550 | 3.458.610 | 1.231 | 1.273 | 773 | 2.823 | 1.222.650 | 4.735.010 | 1.582 | 1.677 | 773 | 100,00 | 1.582 | 100,00 | -4 | -1 | 106 | 4 | 351 | 28 | 404 | 32 |
| | **សរុប ក** | **5.023** | **20.938** | **6.223.828** | **26.869.764** | **1.239** | **1.283** | **3.882** | **21.087** | **6.268.996** | **35.460.761** | **1.615** | **1.682** | **1.051** | **37,12** | **-120** | **-6,90** | **-1.141** | **-23** | **149** | **1** | **376** | **30** | **398** | **31** |
| ខ | **ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច** | 10.000 | 54.900 | 12.390.906 | 70.925.993 | 1.239 | 1.292 | 12.400 | 65.300 | 20.025.336 | 109.245.116 | 1.615 | 1.673 | 300 | 2,48 | -120 | -6,90 | 2.400 | 24 | 10.400 | 19 | 376 | 30 | 381 | 29 |
| | **សរុបI=ក+ខ** | 15.023 | 75.838 | 18.614.734 | 97.795.757 | 1.239 | 1.290 | 16.282 | 86.387 | 26.294.332 | 144.705.877 | 1.615 | 1.675 | 1.351 | 9,05 | -120 | -6,90 | 1.259 | 8 | 10.549 | 14 | 376 | 30 | 386 | 30 |
| | **II. កៅស៊ូគ្រួសារ** | 13.300 | 75.800 | 16.479.905 | 97.971.286 | 1.239 | 1.292 | 14.400 | 75.700 | 23.255.229 | 126.648.135 | 1.615 | 1.673 | 400 | 2,86 | -120 | -6,90 | 1.100 | 8 | -100 | 0 | 376 | 30 | 381 | 29 |
| | **សរុបI+II** | **28.323** | **151.638** | **35.094.638** | **195.767.043** | **1.239** | **1.291** | **30.682** | **162.087** | **49.549.561** | **271.354.012** | **1.615** | **1.674** | **1.751** | **6,05** | **-120** | **-6,90** | **2.359** | **8** | **10.449** | **7** | **376** | **30** | **383** | **30** |

**បញ្ជាក់៖**

១. ក្នុងខែកក្កដា ឆ្នាំ២០២១ ចំណូលពីការនាំចេញជ័រកៅស៊ូចំនួន៤៩ ៥៤៩ ៥៦១ដុល្លារ និងរហូតមកដល់ខែកក្កដា ឆ្នាំ២០២១ ចំណូលសរុបចំនួន២៧១ ៣៥៤ ០១២ដុល្លារ។

២. ក្នុងខែកក្កដា ឆ្នាំ២០២១ បរិមាណបញ្ចេញលក់សរុបមានចំនួន៣០ ៦៨២តោន បានកើនឡើង១ ៧៥១តោន(=+៦,០៥%)ធៀបនឹងខែមុន និងកើនឡើងចំនួន២ ៣៥៩តោន(=+៨%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

៣. ក្នុងខែកក្កដា ឆ្នាំ២០២១ ថ្លៃលក់មធ្យមគឺ១ ៦១៥ដុល្លារ/តោន បានថយចុះចំនួន១២០ដុល្លារ/តោន(=-៦,៩០%)ធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងចំនួន៣៧៦ដុល្លារ/តោន(=+៣០%)ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

៤. រហូតមកដល់ខែកក្កដា ឆ្នាំ២០២១ បរិមាណបញ្ចេញលក់សរុបមានចំនួន១៦២ ០៨៧តោន បានកើនឡើង១០ ៤៤៩តោន(=+៧%)ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

៥. រហូតមកដល់ខែកក្កដា ឆ្នាំ២០២១ ថ្លៃលក់មធ្យមគឺ១ ៦៧៤ដុល្លារ/តោន បានកើនឡើងចំនួន៣៨៣ដុល្លារ/តោន(=+៣០%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

ហ៊ីន-សាផន

ថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២១
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

# ព័ត៌មានថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារជាមធ្យមតាមតំបន់នៅកម្ពុជា

## ប្រចាំខែកក្កដា ឆ្នាំ២០២១

| ល.រ | ខេត្ត | សប្ដាហ៍ទី ១ | | | | | | សប្ដាហ៍ទី ២ | | | | | | សប្ដាហ៍ទី ៣ | | | | | | សប្ដាហ៍ទី ៤ | | | | | | ថ្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | ៛/គ.ក្រ | US$/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | US$/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្ដាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | ៛/គ.ក្រ |
| ១ | ត្បូងឃ្មុំ | 5.800 | 1,42 | → 0 | 2.550 | 0,63 | → 0 | 5.700 | 1,40 | ↓ 100 | 2.500 | 0,61 | ↓ 50 | 5.700 | 1,40 | → 0 | 2.500 | 0,61 | → 0 | 5.600 | 1,38 | ↓ 100 | 2.500 | 0,61 | → 0 | 5.700 | 2.513 |
| ២ | ក្រចេះ | 6.000 | 1,47 | → 0 | 2.600 | 0,64 | → 0 | 6.000 | 1,47 | → 0 | 2.600 | 0,64 | → 0 | 6.000 | 1,47 | → 0 | 2.600 | 0,64 | → 0 | 6.000 | 1,47 | → 0 | 2.600 | 0,64 | → 0 | 6.000 | 2.600 |
| ៣ | កំពង់ធំ | 5.900 | 1,45 | → 0 | 2.600 | 0,64 | → 0 | 5.800 | 1,42 | ↓ 100 | 2.500 | 0,61 | ↓ 100 | 5.800 | 1,42 | → 0 | 2.500 | 0,61 | → 0 | 5.800 | 1,42 | → 0 | 2.500 | 0,61 | → 0 | 5.825 | 2.525 |
| ៤ | កំពង់ចាម | 6.000 | 1,47 | → 0 | 3.000 | 0,74 | → 0 | 6.000 | 1,47 | → 0 | 3.000 | 0,74 | → 0 | 6.000 | 1,47 | → 0 | 2.500 | 0,61 | ↓ 500 | 6.000 | 1,47 | → 0 | 2.500 | 0,61 | → 0 | 6.000 | 2.750 |
| ៥ | រតនគិរី | 6.200 | 1,52 | → 0 | 3.200 | 0,79 | → 0 | 5.900 | 1,45 | ↓ 300 | 2.900 | 0,71 | ↓ 300 | 5.800 | 1,42 | ↓ 100 | 2.800 | 0,69 | ↓ 100 | 5.800 | 1,42 | → 0 | 2.800 | 0,69 | → 0 | 5.925 | 2.925 |
| ៦ | ស្ទឹងត្រែង | 6.100 | 1,50 | → 0 | 2.900 | 0,71 | → 0 | 5.800 | 1,42 | ↓ 300 | 2.900 | 0,71 | → 0 | 5.800 | 1,42 | → 0 | 2.900 | 0,71 | → 0 | 5.800 | 1,42 | → 0 | 2.900 | 0,71 | → 0 | 5.875 | 2.900 |
| ៧ | ព្រះវិហារ | 5.700 | 1,40 | → 0 | 2.900 | 0,71 | → 0 | 5.700 | 1,40 | → 0 | 2.900 | 0,71 | → 0 | 5.800 | 1,42 | ↑ 100 | 2.900 | 0,71 | → 0 | 5.700 | 1,40 | ↓ 100 | 2.900 | 0,71 | → 0 | 5.725 | 2.900 |
| ៨ | មណ្ឌលគិរី | | | | 3.200 | 0,79 | → 0 | | | | 2.900 | 0,71 | ↓ 300 | | | | 3.000 | 0,74 | ↑ 100 | | | | 3.000 | 0,74 | → 0 | | 3.025 |
| ៩ | ពោធិ៍សាត់ | | | | 3.200 | 0,79 | → 0 | | | | 3.000 | 0,74 | ↓ 200 | | | | 3.000 | 0,74 | → 0 | | | | 3.000 | 0,74 | → 0 | | 3.050 |
| ១០ | កំពត | | | | 2.800 | 0,69 | → 0 | | | | 3.100 | 0,76 | ↑ 300 | | | | 3.100 | 0,76 | → 0 | | | | 3.100 | 0,76 | → 0 | | 3.025 |
| ១១ | ប៉ៃលិន | | | | 3.000 | 0,74 | → 0 | | | | 3.000 | 0,74 | → 0 | | | | 3.100 | 0,76 | ↑ 100 | | | | 3.200 | 0,79 | ↑ 100 | | 3.075 |
| ១២ | ឧត្តរមានជ័យ | | | | 3.100 | 0,76 | → 0 | | | | 3.100 | 0,76 | → 0 | | | | 3.100 | 0,76 | → 0 | | | | 3.100 | 0,76 | → 0 | | 3.100 |
| ១៣ | បាត់ដំបង | | | | 3.100 | 0,76 | → 0 | | | | 3.250 | 0,80 | ↑ 150 | | | | 3.350 | 0,82 | ↑ 100 | | | | 3.350 | 0,82 | → 0 | | 3.263 |
| ១៤ | កោះកុង | | | | 3.100 | 0,76 | → 0 | | | | 3.000 | 0,74 | ↓ 100 | | | | 3.000 | 0,74 | → 0 | | | | 3.000 | 0,74 | → 0 | | 3.025 |
| | **ថ្លៃមធ្យម** | **5.957** | **1,46** | → 0 | **2.946** | **0,72** | → 0 | **5.843** | **1,43** | ↓ 114 | **2.904** | **0,71** | ↓ 43 | **5.843** | **1,44** | → 0 | **2.882** | **0,71** | ↓ 21 | **5.814** | **1,43** | ↓ 29 | **2.889** | **0,71** | ↑ 7 | 5.864 | 2.905 |
| | អត្រាប្ដូរប្រាក់ ធនាគារជាតិនៃកម្ពុជា | | 4.071 | | | | | | 4.072 | | | | | | 4.071 | | | | | | 4.072 | | | | | $ 1,47 | $ 0,73 |

បញ្ជាក់៖
*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*
*ទឹកជ័រ: គិតជាស្ងួត (DRC=100%)*
*ជ័រកក: DRC ≅ 50%*

ក្នុងខែកក្កដា ឆ្នាំ២០២១ ថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ(DRC=១០០%) ថ្លៃ៥៧០០០៛-៦០០០៛/គ.ក្រ (បានថយចុះ ៣២០៛/គ.ក្រ ធៀបខែមុន) និងជ័រកក(DRC≅ 50%) ថ្លៃ២៥១៣៛-៣២៦៣៛/គ.ក្រ (បានថយចុះ ៤៨៛/គ.ក្រ ធៀបខែមុន) អាស្រ័យតាមរយៈពេលបង្កក និងតំបន់។

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ីន-សារ៉ុន

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២១
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានកៅស៊ូ**
**នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ**

## តារាងបរិមាណផលិតផលឈើកៅស៊ូកែច្នៃ និងនាំចេញប្រចាំខែកក្កដា ឆ្នាំ២០២១

| ល.រ | ប្រភេទផលិតផលឈើកៅស៊ូ | បរិមាណកែច្នៃ($ម^3$) | | បរិមាណនាំចេញ($ម^3$) | | ថ្លៃឯកត្តា | ចំណូលសរុបដុល្លារ | | សន្និធិ | ប្រទេសគោលដៅនាំចេញ |
|---|---|---|---|---|---|---|---|---|---|---|
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | (ដុល្លារ/$ម^3$) | ខែនេះ | ដល់ខែនេះ | ($ម^3$) | |
| ១ | S4S | 100 | 2861 | 100 | 2861 | 160 | 16.000,00 | 456.910,00 | | ក្នុងស្រុក |
| ២ | Finger Joint | 0 | 708 | 159 | 529 | 490 | 77.910,00 | 252.207,22 | 179 | |
| ៣ | Plywood | 0 | 850 | 152 | 684 | 300 | 45.600,00 | 187.385,62 | 166 | |
| **សរុប** | | 100 | 4419 | 411 | 4074 | | 139.510,00 | 896.502,84 | 345 | |

**ប្រភព៖** រោងចក្រ សិប្បកម្មកែច្នៃឈើកៅស៊ូ

ថ្ងៃច័ន្ទ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២១

**បានឃើញនិងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**សាំង សារ៉េន**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ**

**អ្នកធ្វើតារាង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ

# ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែកក្កដា ឆ្នាំ២០២១

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០២០ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២១ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | ចៀវជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | | | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 754 | 81 | 835 | 45 | 188 | 45 | 190 | 38 | 80 | 478 | 110 | 481 | 0 | 0 | 0 | 0 | 10 | 10 | 35 | 77 | 290 | 154 | 65 | 144 | 291 | 153 | 35 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន គ្រុប | 11,408 | 1,602 | 13,010 | 1,694 | 8,856 | 2,317 | 9,085 | 1,767 | 1,673 | 9,744 | 1,249 | 9,106 | 0 | 0 | 10 | 1 | -93 | -7 | -21 | -1 | 889 | 10 | -1,068 | -46 | 21 | 0 | 2,405 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1,298 | 1,100 | 2,399 | 146 | 612 | 126 | 609 | 176 | 161 | 747 | 210 | 840 | 0 | 0 | 29 | 22 | 210 | 100 | 15 | 10 | 136 | 22 | 84 | 67 | 231 | 38 | 83 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 7,168 | 1,255 | 8,423 | 552 | 2,378 | 769 | 2,591 | 550 | 545 | 2,418 | 541 | 2,270 | 0 | 0 | -26 | -5 | 77 | 17 | -7 | -1 | 39 | 2 | -229 | -30 | -321 | -12 | 698 |
| 5 | ក្រុមហ៊ុនស៊ីហ្វ ភាប់បើ លីមីតធីត(រតនគិរី) | 1,524 | 1,200 | 2,724 | 55 | 205 | - | 169 | 68 | 45 | 257 | | 225 | 0 | 0 | 0 | 1 | 0 | 0 | -11 | -19 | 52 | 25 | 0 | 0 | 56 | 33 | 99 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វែសសស់ លីមីធីត(ស្នួល) | 4,174 | 76 | 4,250 | 509 | 1,902 | 383 | 2,343 | 1,778 | 401 | 2,066 | 499 | 3,181 | 0 | 0 | -50 | -11 | 74 | 17 | -108 | -21 | 164 | 9 | 116 | 30 | 838 | 36 | 663 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 3,908 | 278 | 4,186 | 352 | ,1,376 | 420 | 1,936 | 976 | 300 | 1,145 | 300 | 1,510 | 0 | 0 | -80 | -21 | -50 | -14 | -52 | -15 | -231 | -17 | -120 | -29 | -426 | -22 | 611 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 3,712 | 1,170 | 4,882 | 199 | 851 | 135 | 838 | 672 | 109 | 523 | 100 | 348 | 0 | 0 | 5 | 5 | 0 | 0 | -90 | -45 | -328 | -39 | -35 | -26 | -490 | -58 | 847 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+មោសហែក) | 2,037 | 1,000 | 3,037 | 92 | 437 | 50 | 459 | 477 | 91 | 380 | 100 | 302 | 0 | 0 | 8 | 10 | 50 | 100 | -2 | -2 | -57 | -13 | 50 | 100 | -157 | -34 | 555 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4,731 | 67 | 4,798 | 569 | 2,798 | 777 | 2,717 | 1,234 | 462 | 1,999 | 773 | 2,823 | 0 | 0 | 46 | 11 | 773 | 100 | -107 | -19 | -799 | -29 | -4 | -1 | 106 | 4 | 410 |
| | សរុប ក | 40,716 | 7,829 | 48,545 | 4,215 | 19,603 | 5,023 | 20,938 | 7,736 | 3,867 | 19,757 | 3,882 | 21,087 | 0 | 0 | -58 | -1 | 1,051 | 37 | -348 | -8 | 154 | 1 | -1,141 | -23 | 149 | 1 | 6,406 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 123,849 | 70,605 | 194,454 | 9,300 | 55,800 | 10,000 | 54,900 | 11,283 | 12,800 | 67,300 | 12,400 | 65,300 | 0 | 0 | 400 | 3 | 300 | 2 | 3500 | 38 | 11,500 | 21 | 2,400 | 24 | 10,400 | 19 | 13,283 |
| | សរុបI=ក+ខ | 164,566 | 78,434 | 243,000 | 13,515 | 75,403 | 15,023 | 75,838 | 19,019 | 16,667 | 87,057 | 16,282 | 86,387 | 0 | 0 | 342 | 2 | 1,351 | 9 | 3152 | 23 | 11,654 | 15 | 1,259 | 8 | 10,549 | 14 | 19,689 |
| | II. កៅស៊ូគ្រួសារ | 149,753 | 11,407 | 161,160 | 13,600 | 77,800 | 13,300 | 75,800 | 10,900 | 14,800 | 77,900 | 14,400 | 75,700 | 0 | 0 | 400 | 3 | 400 | 3 | 1200 | 9 | 100 | 0 | 1,100 | 8 | -100 | 0 | 13,100 |
| | សរុបរួមI+II | 314,319 | 89,841 | 404,160 | 27,115 | 153,203 | 28,323 | 151,638 | 29,919 | 31,467 | 164,957 | 30,682 | 162,087 | 0 | 0 | 742 | 2 | 1,751 | 6 | 4352 | 16 | 11,754 | 8 | 2,359 | 8 | 10,449 | 7 | 32,789 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន៤០៤ ១៦០ ហត ( ផ្ទៃដីចៀវជ័រ ៣១៤ ៣១៩ហត ថែទាំ ៨៩ ៨៤១ហត) ។

(២) ផលិតផលក្នុងខែកក្កដាមានចំនួន ៣១ ៤៦៧តោន បានកើនឡើងចំនួន៧៤២ តោន (២ %) ធៀបនឹងខែមុននិងបានកើនឡើង៤ ៣៥២តោន(១៦%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

(៣) រហូតមកដល់ខែកក្កដា ឆ្នាំ២០២១ ផលិតផលសរុប១៦៤ ៩៥៧ តោន បានកើនឡើង១១ ៧៥៤តោន ( ៨%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

(៤) ការបញ្ចេញលក់ក្នុងខែកក្កដាចំនួន៣០ ៦៨២តោន បានកើនឡើងចំនួន១ ៧៥១តោន (៦%)ធៀបនឹងខែមុននិងបានកើនឡើងចំនួន២ ៣៥៩(៨%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

(៥) រហូតមកដល់ខែកក្កដា ឆ្នាំ២០២១ ការបញ្ចេញលក់សរុបចំនួន១៦២ ០៨៧តោន បានកើនឡើងចំនួន១០ ៤៤៩តោន (៧%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

(៦)សន្និធិចុងគ្រាមានចំនួន ៣២ ៧៨៩តោន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

អ៊ួន សុវណ្ណ

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ

ក្រុង ផ្លូស៊ីនី

ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២១
អ្នកធ្វើតារាង

ឃាត់ ឈើម៉ើង